ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ : ១៧៩/១៦ គ.ជ.ប.ជ

# កំណត់ហេតុ
# កិច្ចប្រជុំត្រៀមរៀបចំទិវាជាតិ
# ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ២០១៦

ឆ្នាំពីរពាន់ដប់ប្រាំមួយ ខែតុលា ថ្ងៃទីដប់បួន វេលាម៉ោងដប់បួន និងសាមសិបនាទី នៅសាលប្រជុំអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ មានបើកកិច្ចប្រជុំពិភាក្សាត្រៀមរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ២០១៦ ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ។

សមាសភាពចូលរួមកិច្ចប្រជុំរួមមានតំណាងក្រសួងមហាផ្ទៃ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកិច្ចការនារី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សាលារាជធានីភ្នំពេញ កងរាជអាវុធហត្ថផ្ទៃប្រទេស អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងអង្គការ UN-ACT ។

គោលបំណងនៃកិច្ចប្រជុំគឺ រៀបចំគណៈកម្មការ និងអនុគណៈកម្មការ ដើម្បីរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៦ ព្រមធ្វើការពិភាក្សាអំពីផែនការសកម្មភាព និងការងារដែលត្រូវធ្វើ ដើម្បីឲ្យកម្មវិធីនេះប្រព្រឹត្តទៅដោយរលូន និងទទួលបានជោគជ័យ ។

បន្ទាប់ពីបានប្រជុំពិភាក្សាចូលរួមយោបល់ពីគ្រប់ស្ថាប័ន-អង្គភាពរួចមក អង្គប្រជុំទទួលបានលទ្ធផលដូចខាងក្រោម ៖

**ក. អំពីពិធី**

- បានទទួលគោលការណ៍ពី សម្តេចនាយករដ្ឋមន្ត្រី ឲ្យរៀបចំទិវានេះនៅកោះពេជ្យ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ ។
- អ្នកចូលរួមប្រហែលជាង ៣ពាន់នាក់ ។
- មានកម្មវិធី របៀបវារៈ សុន្ទរកថា ពាក្យស្លោក បដា ការសម្តែងសិល្បៈ ពិធីបង្ហោះប៉េងប៉ោង និងបទយកការណ៍ ។ល។
- មានវត្ថុអនុស្សាវរីយ៍ចែកជូនដូចជា អាវ កាតាប ថង់ និងឯកសារ ។ល។
- សារដែលនឹងផ្សព្វផ្សាយគឺជាសារបែបគោលនយោបាយ ។
- លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ចង់ឲ្យថ្នាក់ដឹកនាំចូលរួមឲ្យបានច្រើន ដើម្បីឲ្យដឹងថាយើងកំពុងធ្វើអ្វី និងឲ្យក្រសួងស្ថាប័នទាំងអស់ចូលរួមសហការជាមួយយើងឲ្យបានកាន់តែប្រសើរ ។

**ខ. ការងារ ភារកិច្ច និងការទទួលខុសត្រូវរបស់អនុគណៈកម្មការ**

អង្គប្រជុំបានបែងចែកអនុគណៈកម្មការដូចឆ្នាំមុន (ឆ្នាំ២០១៥មានអនុគណៈកម្មការចំនួន ៤) តែនឹងមានការផ្លាស់ប្តូរសមាសភាពមួយចំនួនទៅតាមការចាត់តាំងរបស់ស្ថាប័ន-អង្គភាពសាមី ដែលពេលនេះមិនទាន់

បានបញ្ជូនឈ្មោះមកគ្រប់នៅឡើយ ។ ដោយសារថ្ងៃពិធីខិតជិតមកដល់ អង្គប្រជុំបានធ្វើការប្រគល់ភារកិច្ច និងការទទួលខុសត្រូវជូនអនុគណៈកម្មការចំនួន ៣ ជាបណ្តោះអាសន្ន ដើម្បីចាប់ផ្តើមដំណើរការការងារជាបណ្តើរៗចាប់ពីពេលឥឡូវ ក្នុងនោះមានៈ

១. អនុគណៈកម្មការផ្សព្វផ្សាយ និងខ្លឹមសារ

- ត្រូវចាប់ផ្តើមរៀបចំរបៀបវារៈ សុន្ទរកថា ពាក្យស្លោក បដា និងបទយកការណ៍ ។ល។
- ក្រុមការងារក្រសួងទាំង៦ ត្រូវកសាងឯកសារ បង្កើតបទយកការណ៍ ដោយរំលេចយកខ្លឹមសារតាមស្ថាប័នរបស់ខ្លួនដាក់បញ្ចូលជាសារនយោបាយ ។

២. អនុគណៈកម្មការពិធីការ និងសិល្បៈ

- ត្រូវរៀបចំដំណើរការមុនគេពីឥឡូវអំពីការសម្តែងសិល្បៈ ដែលផ្តោត លើ ៣ចំណុចសំខាន់គឺ គោលបំណង ខ្លឹមសារ និងទម្រង់នៃការសម្តែង ។ អ្នកសហការរួមគ្នារៀបចំមានដូចជា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងអបរំ យុវជន និងកីឡា ក្រសួងកិច្ចការនារី និង គ.ជ.ប.ជ ។

៣. អនុគណៈកម្មការសន្តិសុខ សណ្តាប់ធ្នាប់ និងសុខុមាលភាព

- អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានភស្តុភារ និងកងរាជអាវុធហត្ថលើផ្ទៃប្រទេសត្រូវធ្វើការសហការរួមគ្នាតាមជំនាញ និងបទពិសោធន៍ដែលធ្លាប់ធ្វើកន្លងមក ដើម្បីត្រៀមជាស្រេចសម្រាប់ពិធី កុំឲ្យមានការខ្វះចន្លោះកើតឡើង ។

ការងារ ភារកិច្ច និងការទទួលខុសត្រូវរបស់អនុគណៈកម្មការនីមួយៗគឺដូចទៅនឹងឆ្នាំមុនដែរ តែអាចនឹងមានការកែសម្រួលខ្លះទៅតាមស្ថានភាពចាំបាច់ ។

លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ បានមានប្រសាសន៍ថាៈ

- ស្ថាប័ន-អង្គភាពដែលមិនទាន់បានផ្ញើឈ្មោះសមាសភាពអនុគណៈកម្មការមក សូមផ្ញើមកឲ្យបានឆាប់ ព្រោះពេលវេលាកាន់តែខិតជិតមកដល់ហើយ ។
- ស្ថាប័ន-អង្គភាពនីមួយៗត្រូវជួយសម្រួលក្នុងការបញ្ជូនលិខិតអញ្ជើញ ។
- សមាជិកអនុគណៈកម្មការនីមួយៗត្រូវទំនាក់ទំនង និងសហការគ្នាឲ្យបានល្អប្រសើរក្នុងការត្រៀមរៀបចំចាប់ពីឥឡូវ ។
- យើងត្រឡប់ទៅវិញត្រូវនាំគ្នាគិតថាគួរធ្វើកម្មវិធីអ្វីទៀត ដើម្បីឲ្យមានភាពថ្មីប្លែក និងទទួលបានការគាំទ្រកាន់តែខ្លាំង កុំឲ្យដដែលៗ ។

កិច្ចប្រជុំបានប្រព្រឹត្តទៅយ៉ាងផុលផុស និងបានបញ្ចប់នៅវេលាម៉ោងដប់ប្រាំមួយ និងសាមសិបនាទីល្ងាចថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសស្និទ្ធស្នាល និងក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ។

ភ្នំពេញ ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៦

**អ្នកកត់ត្រា**

ជុំ.រតនៈ

គោរពជូន លោកជំទាវ

អនុប្រធានអចិន្ត្រៃយ៍ មេត្តាជ្រាបជាព័ត៌មាន ។

ភ្នំពេញ ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦

**ប្រធានលេខាធិការដ្ឋាន**

ឧត្តមសេនីយ៍ត្រី **គង់ ពុទ្ធី**

និងឯកសារ 24/10/2016

**សមាសភាពចូលរួមកិច្ចប្រជុំ**

**ត្រៀមរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ២០១៦**

**នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦**

| | | | |
|---|---|---|---|
| - លោកជំទាវ | ជូ ប៊ុនអេង | រដ្ឋលេខាធិការ | អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ |
| - ឯកឧត្តម ឧ.ឯក | ថោង សំអាត | អគ្គលេខាធិការ | គ.ជ.ប.ជ |
| - ឯកឧត្តម ឧ.ឯក | ខៀវ ចាន់រ៉ា | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| - ឯកឧត្តម ឧ.ឯក | ស៊ុន វ៉ូ | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| - ឯកឧត្តម ឧ.ទោ | យ៉ែម ច័ន្ទណារុំ | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| - ឯកឧត្តម ឧ.ទោ | អ៊ូ ម៉ានីរ៉ា | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| - លោកជំទាវ | រ៉ែន សិរីលក្ខិណា | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| - លោកជំទាវ | ប៊ុន ពុទ្ធី | អនុរដ្ឋលេខាធិការ | ក្រសួងកិច្ចការនារី |
| - លោកជំទាវ | សឿ សុជាតា | អនុរដ្ឋលេខាធិការ | ក្រសួងអប់រំ យុវជន និងកីឡា |
| - លោក | តិប សុផល | អនុប្រធានការិយាល័យ | ក្រសួងអប់រំ យុវជន និងកីឡា |
| - លោក | សុក សុង | អនុប្រធាននាយកដ្ឋាន | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| - លោកស្រី | កែវ ម៉ាលី | អនុប្រធាននាយកដ្ឋាន | ក្រសួងសង្គមកិច្ច |
| - ឯកឧត្តម ឧ.ឯក | ជា សារិន | មេបញ្ជាការរង | អាវុធហត្ថផ្ទៃប្រទេស |
| - អនុសេនីយ៍ឯក | រ៉ា បញ្ញា | នាយផ្នែក | អាវុធហត្ថផ្ទៃប្រទេស |
| - លោកស្រី | ម៉ន វិមាន | អនុប្រធាននាយកដ្ឋាន | អគ្គលេខាធិការដ្ឋាន |
| - លោក | សេ រ៉ាឌី | អនុប្រធានការិយាល័យពិធីការ | អគ្គលេខាធិការដ្ឋាន |
| - ឧត្តមសេនីយ៍ទោ | សុខ សំសោភ័ណ | អនុប្រធាននាយកដ្ឋាន | នាយកដ្ឋានផ្សព្វផ្សាយអប់រំ |
| - ឧត្តមសេនីយ៍ត្រី | ជ័យ បុប្ផា | អនុប្រធាននាយកដ្ឋាន | នាយកដ្ឋានសុខាភិបាល |
| - វរៈសេនីយ៍ឯក | អ៊ី ប៊ុនថា | នាយការិយាល័យ | នាយកដ្ឋានអង្គរក្ស |
| - លោក | ថៃ ដារ៉ា | ប្រធានការិយាល័យ | សាលារាជធានីភ្នំពេញ |
| - លោក | កាំង លាងគ្រី | នាយករងទីចាត់ការច្បាប់ | សាលារាជធានីភ្នំពេញ |
| - ឧត្តមសេនីយ៍ត្រី | គង់ ពុទ្ធី | ប្រធានលេខាធិការដ្ឋានស្ដីទី | គ.ជ.ប.ជ |
| - លោក | ឆេង វណ្ណា | អនុប្រធានលេខាធិការដ្ឋាន | គ.ជ.ប.ជ |
| - វរៈសេនីយ៍ត្រី | អ៊ិន មាន | ជំនួយការអនុប្រធានអចិន្ត្រៃយ៍ | គ.ជ.ប.ជ |
| - អនុសេនីយ៍ត្រី | ថោង សុវត្ថិ | ជំនួយការអនុប្រធានអចិន្ត្រៃយ៍ | គ.ជ.ប.ជ |
| - អនុសេនីយ៍ឯក | ដៀប នួច | នាយរងការិយាល័យ | គ.ជ.ប.ជ |
| - អនុសេនីយ៍ឯក | ហ៊ី រតនៈ | នាយរងការិយាល័យ | គ.ជ.ប.ជ |
| - លោក | លឹម ទិត្យ | អ្នកសម្របសម្រួល | UN-ACT |